**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៨៧៤ ប្រក

# ប្រកាស

## ស្តីពី

## របៀបរបបការងារនិងការប្រគល់សិទ្ធិលើការងារតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ

---

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតអគ្គនាយកដ្ឋានធនធានមនុស្ស ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣០៣ អនក្រ.បក ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំនៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ១១០១ ប្រក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកំណត់មុខតំណែងសមមូលនិងមុខតំណែងមូលដ្ឋាននៃប្រាក់បំណាច់មុខងាររបស់មន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ១.-**

ត្រូវបានកំណត់របៀបរបបការងារនិងការប្រគល់សិទ្ធិលើការងារតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ ជូនអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល។

ប្រការ២..

កំណត់អំពីរបៀបរបបការងារតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំវេទាសម្ព័ន្ធ ដូចខាងក្រោម៖

១- សមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល ត្រូវលើកសំណើតាមឋានានុក្រមជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រួចបញ្ជូនសំណុំឯកសារទៅអគ្គនាយកដ្ឋានធនធានមនុស្ស ដែលជាសេនាធិការក្នុងការលើកយោបល់និងរៀបចំបែបបទតាមនីតិវិធីដាក់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យនិងសម្រេច។

២- សមត្ថកិច្ចរបស់អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ

គ្រប់នាយកដ្ឋាន អង្គភាព ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងថ្នាក់ប្រហាក់ប្រហែល ត្រូវលើកសំណើតាមរយៈការិយាល័យបុគ្គលិក ដើម្បីរៀបចំបែបបទស្នើសុំគោលការណ៍ពីអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ រួចបញ្ជូនសំណុំឯកសារទៅអគ្គនាយកដ្ឋានធនធានមនុស្ស ដើម្បីពិនិត្យផ្តល់ទិដ្ឋាការ និងរៀបចំបែបបទជូនអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ពិនិត្យនិងសម្រេច។

៣- សមត្ថកិច្ចរបស់អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល

គ្រប់នាយកដ្ឋាន អង្គភាព និងថ្នាក់ប្រហាក់ប្រហែល ត្រូវលើកសំណើសុំគោលការណ៍ពីអគ្គនាយកនៃអគ្គនាយកដ្ឋានសាមី រួចបញ្ជូនសំណុំឯកសារទៅអគ្គនាយកដ្ឋានធនធានមនុស្ស ដើម្បីពិនិត្យផ្តល់ទិដ្ឋាការ និងរៀបចំបែបបទជូនអគ្គនាយកនៃអគ្គនាយកដ្ឋានសាមី ពិនិត្យនិងសម្រេច។

ប្រការ៣..

កំណត់លក្ខណសម្បត្តិ បែបបទ និងនីតិវិធីនៃការតែងតាំងមុខតំណែង និងដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ដូចខាងក្រោម៖

១- លក្ខណសម្បត្តិ

- មានមនសិការស្នេហាជាតិ ស្មោះត្រង់ និងមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ
- គោរពនិងប្រតិបត្តិបានម៉ឺងម៉ាត់នូវរាល់បទបញ្ជាផ្ទៃក្នុង គោលនយោបាយ និងច្បាប់របស់រដ្ឋ
- មានគំនិតផ្តួចផ្តើមច្នៃប្រឌិត មុខជំនាញវិជ្ជាជីវៈច្បាស់លាស់ ឧស្សាហ៍ព្យាយាម សកម្មការងារ និងស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងមានបទពិសោធសមស្រប
- មានសីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើដែលបណ្តាលឱ្យប៉ះពាល់ដល់កិត្យានុភាពអង្គភាព និងកិត្តិយសរបស់ជាតិ
- មានសាមគ្គីភាពល្អ ទំនាក់ទំនងទូលំទូលាយជាមួយមន្ត្រីរួមការងារ និងសមត្ថកិច្ចពាក់ព័ន្ធ
- ចេះកៀរគរកម្លាំងសាធារណៈចូលរួមសហការបំពេញភារកិច្ចសម្រេចបានលទ្ធផលល្អ
- ជាសេវាបម្រើ ជាអ្នកការពារដ៏ស្មោះត្រង់ និងទទួលបានទំនុកចិត្តពីអង្គភាពនិងប្រជាពលរដ្ឋ
- មានសមត្ថភាពគ្រប់គ្រងបញ្ជាដឹកនាំនិងបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាព មានការគោរពស្រឡាញ់ជឿទុកចិត្តពីមន្ត្រីក្រោមឱវាទនិងប្រជាពលរដ្ឋ
- មានសុខភាពល្អនិងកាយសម្បទាមាំមួន
- បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញនគរបាលជាតិយ៉ាងតិចពីរខែកន្លះឡើង។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

២- បែបបទ

រាល់ការតែងតាំងមុខតំណែង និងដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមរបៀបរបបការងារ គោលការណ៍ លក្ខណសម្បត្តិ និងត្រូវបំពេញបែបបទ ដូចខាងក្រោម៖

- សំណើរបស់អង្គភាពសាមី តាមឋានានុក្រម
- កំណត់ហេតុប្រជុំពិភាក្សាវាយតម្លៃរបស់ថ្នាក់ដឹកនាំអង្គភាពសាមី
- តារាងព្រឹត្តបត្រពិន្ទុរបស់មន្ត្រីនគរបាលជាតិ
- ប្រវត្តិរូបសង្ខេបរបស់មន្ត្រីនគរបាលជាតិ
- លិខិតឯកត្តកម្មតែងតាំងមុខតំណែង និងដំឡើងឋានន្តរស័ក្តិចុងក្រោយ
- សញ្ញាបត្រ វិញ្ញាបនបត្រ លិខិតបញ្ជាក់ការសិក្សា ទាក់ទងទៅនឹងជំនាញឯកទេសផ្សេងៗ ជាពិសេសទាក់ទងទៅនឹងជំនាញនគរបាលដែលបានឆ្លងវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស។

៣- នីតិវិធី

ក- ការតែងតាំងមុខតំណែង

- ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ ត្រូវពិនិត្យលក្ខណសម្បត្តិ សមត្ថភាព អតីតភាព បទពិសោធ និងបានទទួលការបណ្តុះបណ្តាលមុខជំនាញនគរបាលជាតិ
- ការតែងតាំងត្រូវឱ្យសមស្របទៅតាមតម្រូវការនៃការងារ និងការកំណត់ចំនួនមុខតំណែង នៅក្នុងរចនាសម្ព័ន្ធ ហើយមិនអនុញ្ញាតធ្វើការតែងតាំងផ្លោះមុខតំណែងឡើយ
- ប្រធានអង្គភាពត្រូវរៀបចំបញ្ជីមន្ត្រីនគរបាលជាតិដែលនឹងត្រូវស្នើសម្រាប់ការតែងតាំង ផ្អែកតាមលក្ខណសម្បត្តិដែលបានកំណត់។

ខ- ការដំឡើងឋានន្តរស័ក្តិ

- ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ត្រូវគិតទៅលើលក្ខណសម្បត្តិ និងអតីតភាពការងារ
- ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ត្រូវប្រព្រឹត្តទៅតាមលំដាប់ថ្នាក់មួយស័ក្តិម្តងៗ ហើយពុំអាចមានការតែងតាំងឋានន្តរស័ក្តិកិត្តិយសបានឡើយ។ ក្នុងករណីមន្ត្រីនគរបាលជាតិណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេស ត្រូវបានដំឡើងឋានន្តរស័ក្តិមួយថ្នាក់ដោយពុំគិតពីលក្ខខណ្ឌ និងអតីតភាពការងារឡើយ
- ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ត្រូវប្រព្រឹត្តទៅតាមលំដាប់នៃបញ្ជីអតីតភាព និងផ្អែកទៅតាមព្រឹត្តិបត្រពិន្ទុរបស់មន្ត្រីនគរបាលជាតិ ព្រមទាំងមានឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិដែលត្រូវរៀបចំឡើងក្នុងមួយឆ្នាំម្តងៗ។ ក្នុងករណីដែលមិនបានជាប់ឈ្មោះក្នុងបញ្ជីដំឡើងឋានន្តរស័ក្តិប្រចាំឆ្នាំទេ មន្ត្រីនគរបាលជាតិនោះត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់ តាមលេខរៀងនៅក្នុងតារាងដំឡើងឋានន្តរស័ក្តិនាឆ្នាំបន្ទាប់ លើកលែងតែរដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្រេចផ្ទុយពីនេះដែលមានសេចក្តីរាយការណ៍សមហេតុសមផលពីមន្ត្រីដែលមានសមត្ថកិច្ច
- ការដំឡើងឋានន្តរស័ក្តិពុំអាចភ្ជាប់ទៅនឹងការតែងតាំងមុខតំណែងបានឡើយ។

ប្រការ៤.-

ការតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ស្ថិតក្រោមសមត្ថកិច្ចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ៖

១- តែងតាំងមុខតំណែង ៖

ក- ថ្នាក់ក្រសួង

- អនុប្រធាននាយកដ្ឋាន អង្គភាព និងថ្នាក់ប្រហាក់ប្រហែល
- នាយ នាយរងការិយាល័យ ចំណុះនាយកដ្ឋាន អង្គភាព និងថ្នាក់ប្រហាក់ប្រហែល
- នាយ នាយរងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិ
- មេបញ្ជាការ មេបញ្ជាការរងវរសេនាតូចការពារព្រំដែនគោក-ទឹក។

ខ- ថ្នាក់រាជធានី ខេត្ត

- ស្នងការ ស្នងការរងនគរបាលរាជធានី ខេត្ត
- នាយ នាយរងការិយាល័យ និងអធិការ អធិការរងនគរបាលក្រុង ស្រុក ខណ្ឌ ចំណុះស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងថ្នាក់ប្រហាក់ប្រហែល
- មេបញ្ជាការ មេបញ្ជាការរងវរសេនាតូចការពារព្រំដែនគោក។

២- ដំឡើងឋានន្តរស័ក្តិ ៖ ចាប់ពីថ្នាក់វរសេនីយ៍ត្រី ដល់ថ្នាក់វរសេនីយ៍ទោ។

៣- ផ្ទេរភារកិច្ច ៖ មន្ត្រីនគរបាលជាតិដែលមានមុខតំណែងចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន អង្គភាព និងថ្នាក់ប្រហាក់ប្រហែលដល់នាយរងការិយាល័យ ឬថ្នាក់ប្រហាក់ប្រហែល និងផ្ទេរមន្ត្រីនគរបាលជាតិពីអគ្គនាយកដ្ឋានមួយទៅអគ្គនាយកដ្ឋានមួយទៀត។

**ប្រការ៥.-**

អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាននានា និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល មានសិទ្ធិតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំចេនាសម្ព័ន្ធ ដូចខាងក្រោម៖

១- អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំចេនាសម្ព័ន្ធ ដូចខាងក្រោម៖

ក- តែងតាំងមុខតំណែង ៖ ចាប់ពីនាយ នាយរងផ្នែកចំណុះការិយាល័យនៃនាយកដ្ឋាន អង្គភាពនិងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងថ្នាក់ប្រហាក់ប្រហែលចុះ។

ខ- ដំឡើងឋានន្តរស័ក្តិ ៖ ចាប់ពីថ្នាក់ពលបាលត្រី ដល់ថ្នាក់អនុសេនីយ៍ឯក។

គ- ផ្ទេរភារកិច្ច ៖ ពីអង្គភាពមួយទៅអង្គភាពមួយចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចាប់ពីថ្នាក់នាយផ្នែក និងថ្នាក់ប្រហាក់ប្រហែលចុះ។

ឃ- រៀបចំចេនាសម្ព័ន្ធ ៖ ចាប់ពីថ្នាក់ផ្នែកចំណុះការិយាល័យនៃនាយកដ្ឋាន អង្គភាព និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត និងថ្នាក់ប្រហាក់ប្រហែលចុះ។

២- អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ដូចខាងក្រោម៖

ក- តែងតាំងមុខតំណែង ៖

- នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃនាយកដ្ឋាន អង្គភាពក្រោមឱ្យ
- នាយ នាយរងផ្នែក ចំណុះប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិ។

d with CamScanner

ខ- ដំឡើងឋានន្តរស័ក្តិ : ចាប់ពីថ្នាក់ពលបាលត្រី ដល់ថ្នាក់អនុសេនីយ៍ឯក។

គ- ផ្ទេរភារកិច្ច : ពីអង្គភាពមួយទៅអង្គភាពមួយចំណុះអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចាប់ពីថ្នាក់នាយផ្នែក និងថ្នាក់ប្រហាក់ប្រហែលចុះ។

ឃ- រៀបចំវចនាសម្ព័ន្ធ : ថ្នាក់ផ្នែកចំណុះការិយាល័យនៃនាយកដ្ឋានក្រោមឱវាទ និងថ្នាក់ផ្នែកចំណុះប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍នគរបាលច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍នគរបាលច្រកទ្វារកំពង់ផែអន្តរជាតិ។

៣- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាទីជីថលនិងផ្សព្វផ្សាយអប់រំ និងប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែល ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំវចនាសម្ព័ន្ធ ដូចខាងក្រោម៖

ក- តែងតាំងមុខតំណែង : នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃនាយកដ្ឋាន អង្គភាពក្រោមឱវាទ និងថ្នាក់ប្រហាក់ប្រហែលចុះ។

ខ- ដំឡើងឋានន្តរស័ក្តិ : ចាប់ពីថ្នាក់ពលបាលត្រី ដល់ថ្នាក់អនុសេនីយ៍ឯក។

គ- ផ្ទេរភារកិច្ច : ពីអង្គភាពមួយទៅអង្គភាពមួយក្រោមឱវាទ ចាប់ពីថ្នាក់នាយផ្នែក និងថ្នាក់ប្រហាក់ប្រហែលចុះ។

ឃ- រៀបចំវចនាសម្ព័ន្ធ : ចាប់ពីថ្នាក់ផ្នែក ចំណុះការិយាល័យនៃនាយកដ្ឋាន អង្គភាពក្រោមឱវាទ និងថ្នាក់ប្រហាក់ប្រហែលចុះ។

**ប្រការ៦.-**

ការផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម៖

- ផ្អែកលើតម្រូវការចាំបាច់នៃការប្រើកម្លាំងជំនាញ ដើម្បីធានានិរន្តរភាពការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម
- ការផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិដែលបម្រើការងារនៅតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងវរសេនាតូចនគរបាលការពារព្រំដែនគោក និងព្រំដែនទឹក ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ០៤៨ សណន ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២។

**ប្រការ៧.-**

ប្រកាសលេខ៤៧៧៣ ប្រ.ក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ ស្តីការប្រគល់សិទ្ធិការផ្ទេរតែងតាំងមុខតំណែង ដំឡើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំវចនាសម្ព័ន្ធ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍និងជំនួសដោយប្រកាសនេះ។

ប្រការ៤..

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ប្រធានក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថលនិងផ្សព្វផ្សាយអប់រំ ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ [illegible]

ថ្ងៃ[illegible] ១០រោច ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

អភិសន្តិបណ្ឌិត ស សុខា

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ